រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

សម្រាប់ការផ្សាយបន្ទាន់
ថ្ងៃ ចន្ទ ទី ៣០ ខែ មករា ឆ្នាំ ២០១២

## របាយការណ៍សំយោគទី ២៧ របស់*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ

## វិស័យកាត់ដេរបន្តការកើនឡើង បើទោះបីជានៅមានបញ្ហាប្រឈមមួយចំនួន ពាក់ព័ន្ធនឹងបញ្ហាការជួលសន្លប់

ភ្នំពេញ ប្រទេសកម្ពុជា- *គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* នៃអង្គការពលកម្មអន្តរជាតិ (ILO) នៅថ្ងៃនេះ ចេញផ្សាយនូវ*របាយការណ៍សំយោគទី ២៧ ស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរកម្ពុជា* ដែលធ្វើការវាយតំលៃលើការអនុលោមតាមច្បាប់ស្តីពីការងាររបស់ប្រទេសកម្ពុជា និងបទដ្ឋានការងារអន្តរជាតិនៅក្នុងរោងចក្រកាត់ដេរនាំចេញ។

របាយការណ៍សំយោគទី ២៧ នេះឆ្លុះបញ្ចាំងពីទិន្នន័យនៃការអនុលោមតាមច្បាប់ ដែលប្រមូលបាននៅចន្លោះពីថ្ងៃទី ១ ខែ ឧសភា ដល់ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១១។ នៅក្នុងរយៈពេល ៦ ខែនេះ ក្នុងចំណោមរោងចក្រសរុបចំនួន ៣០០ ដែលបានចុះបញ្ជិកាជាមួយ*គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា* មានរោងចក្រចំនួន១៦៩ ត្រូវបានធ្វើការត្រួតពិនិត្យនូវល័ក្ខខ័ណ្ឌការងារ។ របាយការណ៍ត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារនេះផ្តល់នូវព័ត៌មានជាច្រើនរួមមានព័ត៌មានអំពីទំហំរោងចក្រនៅទូទាំងវិស័យនេះ ក៏ដូចជាទិន្នន័យប្រៀបធៀបអំពីការអនុលោមតាមសិទ្ធិជាមូលដ្ឋាន និងល័ក្ខខ័ណ្ឌការងារសំខាន់ៗមួយចំនួនដើម្បីសម្រួលដល់ការតាមដាននូវកម្រិតនៃការអនុលោមតាមច្បាប់នាពេលកន្លងមក។

របាយការណ៍នេះបានបង្ហាញពីការកើនឡើងដ៏ខ្ពស់នៃចំនួនកម្មករនិយោជិតរហូតដល់ ៣៤៥៣៦៤ នាក់ បម្រើការងារនៅក្នុងរោងចក្រចំនួន ៣០០ ដែលបានចុះបញ្ជិកាជាមួយគំរោង ដែលចំនួននេះបានកើនឡើងចាប់តាំងពីរបាយការណ៍សំយោគទី២១ ចេញផ្សាយថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៨។ ចំនួនរោងចក្រមានការកើនឡើងចំនួន ៩% ហើយចំនួនកម្មករនិយោជិតក៏កើនឡើងចំនួន ៧%ផងដែរ បើប្រៀបធៀបនឹងរបាយការណ៍មុន។ ៩០.៧% នៃកម្មករនិយោជិតដែលបម្រើការងារ គឺជាកម្មការិនី។

យោងតាមទិន្នន័យក្រសួងពាណិជ្ជកម្ម ការនាំចេញសម្លៀកបំពាក់កាត់ដេរពីប្រទេសកម្ពុជា បានកើនឡើងរហូតដល់ ៣.៤៧ កោនដុល្លារ ក្នុងរយៈពេល ១០ ខែដំបូងនាឆ្នាំ ២០១១ ដែលបានកើនឡើងចំនួន ៣៤% បើប្រៀបធៀបនឹងរយៈពេលដដែលក្នុងឆ្នាំ ២០១០។

Better Factories Cambodia
International Labour Organization

#9, Street 322
Boeung Keng Kang I
Phnom Penh, Cambodia
PO Box 2642

Tel (+855) 23 212 847
(+855) 23 220 362
ext. 106/7
Fax (+855) 23 212 903
E-mail betterfactories@ilo.org
Website www.betterfactories.org/ilo

អំឡុងពេលនៃការធ្វើរបាយការណ៍នេះ មានរោងចក្រកាត់ដេរយ៉ាងហោចណាស់ចំនួន ១១ ជួបនឹងឧបទ្ទវហេតុនៃការដួលសន្លប់ ហើយមានកម្មករនិយោជិតជាង ១៥០០ នាក់ បានរងគ្រោះនូវការដួលសន្លប់ក្នុងម៉ោងធ្វើការ។ ការសិក្សាជាច្រើនបានបង្ហាញពីមូលហេតុមួយចំនួនដែលអាចនាំឱ្យមានការដួលសន្លប់នេះ ដូចជា បញ្ហាអាហារូបត្ថម្ភ អនាម័យ កង្វះខាតអាហារពេលព្រឹក ភាពតានតឹង ប្រព័ន្ធខ្យល់ចេញចូល ការធ្វើការលើសម៉ោងកំណត់ បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ ក៏ដូចជាបញ្ហាអារម្មណ៍ចិត្តសាស្ត្រដែលធ្វើឱ្យកម្មករដួលសន្លប់នៅពេលដែលខ្លួនឃើញកម្មករផ្សេងទៀតដួលសន្លប់នោះ។

របាយការណ៍សំយោគទី ២៧ បង្ហាញថា កម្រិតអនុលោមតាមច្បាប់មួយចំនួន ស្ថិតនៅក្រោម ៥០% សម្រាប់ល័ក្ខខ័ណ្ឌជាច្រើន ដែលពាក់ព័ន្ធនឹងឧបទ្ទវហេតុនៃការដួលសន្លប់ ដូចជា ការងារថែមម៉ោងម្តងម្កាល (៥%) ការងារថែមម៉ោងកម្រិតត្រឹម២ម៉ោងក្នុងមួយថ្ងៃ (១៦%) មានសាប៊ូនិងទឹកគ្រប់គ្រាន់នៅក្បែរបង្គន់អនាម័យ (៤៨%) និងកម្រិតកម្តៅនៅក្នុងរោងចក្រ (៣៨%)។

យោងតាមតួលេខពីសមាគមរោងចក្រកាត់ដេរនៅកម្ពុជា អំឡុងពេលនៃការធ្វើរបាយការណ៍នេះ រោងចក្រកាត់ដេរមានការកើតឡើងនូវកូដកម្មចំនួន ១៤ដង ហើយមានកម្មករចូលរួមចំនួន ១៦៤៩៨ នាក់ ដែលនាំឱ្យខាតបង់នូវចំនួនថ្ងៃធ្វើការ ចំនួន ៨១៥៨៤ ថ្ងៃ។

លទ្ធផលដែលបានរកឃើញសំខាន់ៗមួយចំនួន មានដូចតទៅ ៖

- កម្មករនិយោជិត៣ភាគ៤ ធ្វើការនៅក្នុងរោងចក្រដែលមានកម្មករចំនួន ១០០០ នាក់ឬច្រើនជាងនេះ ប៉ុន្តែរោងចក្រភាគច្រើនដែលត្រូវបានត្រួតពិនិត្យ មានកម្មករនិយោជិតតិចជាង ១០០០ នាក់។
- ៦៦% នៃរោងចក្រ ដែលត្រូវបានពិនិត្យមើលនូវល័ក្ខខ័ណ្ឌការងារ មានសហជីពយ៉ាងហោចណាស់មួយ ពោលគឺបានធ្លាក់ចុះចំនួន ១០% បើធៀបនឹងរបាយការណ៍មុន។
- រោងចក្រដែលបានរើសអើងចំពោះកម្មករនិយោជិត គឺមានចំនួន ១៨% ពោលគឺកើនឡើងពី ១៣%នៅក្នុងរបាយការណ៍មុន ហើយរោងចក្រដែលមានការរើសអើងប្រឆាំងនឹងសហជីពគឺមានចំនួន ៤% ពោលគឺកើនឡើងពី ៣% ចំណែកឯរោងចក្រដែលរំខានដល់សេរីភាពរបស់កម្មករនិយោជិតក្នុងការបង្កើតអង្គការវិជ្ជាជីវៈមានចំនួន ៥% ពោលគឺកើនឡើងពី ២%។
- មន្ត្រីត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ពុំបានរកឃើញនូវពលកម្មដោយបង្ខំឡើយ ប៉ុន្តែរកឃើញនូវកម្មករនិយោជិតស្ថិតក្រោមអាយុធ្វើការដែលកំណត់ដោយច្បាប់ ពោលគឺក្រោមអាយុ១៥ឆ្នាំ ចំនួន ៧នាក់។
- ការអនុលោមតាមការធ្វើការថែមម៉ោងម្តងម្កាល មានចំនួន ៥% ពោលគឺធ្លាក់ចុះពី ៧% ហើយការថែមម៉ោងដែលកំណត់រយៈពេល២ម៉ោងក្នុងមួយថ្ងៃ មានចំនួន ១៦% ពោលគឺធ្លាក់ចុះពី ២៥% បើធៀបនឹងរបាយការណ៍មុន ខណៈពេលដែលការធ្វើការនៅថ្ងៃអាទិត្យដោយស្ម័គ្រចិត្ត និងម្តងម្កាលមានចំនួន ៧០% ពោលគឺកើនឡើងចំនួន ៦%។
- ការអនុលោមតាមការផ្តល់ប្រាក់ឈ្នួលក្នុងការឈប់សម្រាកលំហែមាតុភាព មានចំនួន ៦៥% ពោលគឺធ្លាក់ចុះពី ៧៣% ហើយរោងចក្រដែលផ្តល់ប្រាក់ឧបត្ថម្ភការងារទៀតទាត់ចំនួន៧ដុល្លារ នៅពេលដែលកម្មករឈប់សម្រាកប្រចាំឆ្នាំ មានចំនួន ៦២% ពោលធ្លាក់ចុះពី ៦៨%។

- ការអនុលោមតាមកម្រិតកម្ដៅនៅក្នុងរោងចក្រមានចំនួន ៣៨% ពោលធ្លាក់ចុះ ៤% បើប្រៀបធៀបនឹងរបាយការណ៍មុន ខណៈពេលដែលរោងចក្រដែលផ្ដល់សាប៊ូ និងទឹកគ្រប់គ្រាន់នៅក្បែរបង្គន់អនាម័យមានចំនួន ៤៨% ដែលកើនឡើងចំនួន ១% នៅក្នុងរបាយការណ៍នេះ។

របាយការណ៍សំយោគទី ២៧ ស្ដីពីលក្ខខណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា មានជាភាសា**ខ្មែរ** និង **អង់គ្លេស** ដែលអាចរកបាននៅលើគេហទំព័រ www.betterfactories.org ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:
លោក ប៊ុន យិញ
មន្ត្រីទំនាក់ទំនងព័ត៌មាន
អ៊ីម៉ែល: ying@ilo.org
ទូរស័ព្ទ: (៨៥៥) ២៣ ២១២ ៨៤៧